អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/II/15

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ០៣ មីនា ២០០៨

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
04 / FEB / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNY VUNET

---

សាធារណៈ

## សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវីក្នុងការស្នើសុំពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ញាយុត្តាធិការ

---

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**
ជា លាង
Robert PETIT

**<u>ជនត្រូវចោទ</u>**
អៀង សារី

**<u>សហមេធាវី</u>**
អាង ឧត្តម
Michael G.KARNAVAS

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
04 / FEB / 2008
ម៉ោង (Time/Heure): 13:45'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNY VUNET

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

១- **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”) បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បណ្ដឹងឧទ្ធរណ៍ (“បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន”) របស់ **អៀង សារី** ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ តបទៅនឹងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន លិខិតអញ្ជើញរបស់អង្គបុរេជំនុំជម្រះឲ្យឆ្លើយតបនឹងសេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា អំពី *ការកាត់ទោសពីរដងក្នុងបទល្មើសតែមួយ ការអនុគ្រោះទោស និងការលើកលែងទោស* ចុះថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ព្រមទាំង “សំណើជាបន្ទាន់ក្នុងការស្នើសុំពន្យារពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ” និង“ការឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍អំពីការឃុំខ្លួនបណ្ដោះអាសន្ន តាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ” ដែលមេធាវីបានដាក់ចូលមកនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨។

២- សហមេធាវីបានស្នើឲ្យអង្គបុរេជំនុំជម្រះ៖

ក- យល់ឃើញថា **អៀង សារី** មិនបានបោះបង់សិទ្ធិក្នុងការជំទាស់នឹងយុត្តាធិការ ហើយមានសិទ្ធិសេរីភាពក្នុងការដាក់សារណាជំទាស់បែបនេះទៅសហចៅក្រមស៊ើបអង្កេត

ខ- ឬ អនុញ្ញាតឲ្យសហមេធាវីពន្យារពេលដាក់សារណាអំពីបញ្ហាយុត្តាធិការ រហូតដល់ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាទាំងនេះគួរតែជំនុំជម្រះជាផ្នែកមួយនៃបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន។

៣- វិធាន ៧៧ នៃវិធានផ្ទៃក្នុងចែងពីនីតិវិធីសម្រាប់បណ្ដឹងឧទ្ធរណ៍ និងពាក្យសុំទៅអង្គបុរេជំនុំជម្រះ រួមទាំងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ សហមេធាវីមានឱកាសលើកបញ្ហាទាំងអស់នៅក្នុងបណ្ដឹងឧទ្ធរណ៍តាមដែលខ្លួនចង់លើក ដែលភាគីផ្សេងទៀតអាចឆ្លើយតបបាន។ អង្គបុរេជំនុំជម្រះនឹងចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ បន្ទាប់ពីសវនាការជំនុំជម្រះ។

៤- នៅក្នុងវិធានផ្ទៃក្នុង ពុំមានបទប្បញ្ញត្តិណាដែលអនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះ នៅក្នុងដំណាក់កាលនីតិវិធីនេះយល់ឃើថា **អៀង សារី** មិនបានបោះបង់សិទ្ធិក្នុងការជំទាស់នឹងយុត្តាធិការ ហើយមានសិទ្ធិសេរីភាពក្នុងការដាក់សារណាជំទាស់ណាមួយទៅសហចៅក្រមស៊ើបអង្កេត តាមការស្នើសុំរបស់សហមេធាវីឡើយ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00165505

C22/I/15

៥- ក្នុងកម្រិតដែលថាអង្គបុរេជំនុំជម្រះត្រូវបកស្រាយថា ការឆ្លើយតបរបស់សហមេធាវីជាសំណើសុំកំណត់ពេលដាក់សារណាអំពីបញ្ហាយុត្តាធិការ អង្គបុរេជំនុំជម្រះអនុញ្ញាតតាមសំណើនេះ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពេលវេលាសំណូមពរខាងលើមានលក្ខណៈឬសហេតុ បើពិចារណាលើរយៈពេលដែលបានកំណត់ឲ្យដាក់សារណាពីមុន ទាក់ទងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងការដែលសហមេធាវីត្រូវបានអង្គបុរេជំនុំជម្រះអញ្ជើញឲ្យដាក់សារណាលើបញ្ហានេះ កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨។

៦- ដោយសារតែបញ្ហាវិសាលភាពនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន បច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់គេក្នុងដំណើរការនីតិវិធី បន្ទាប់ពីចេញសេចក្ដីសម្រេចលើបញ្ហានោះរួច។

## អង្គបុរេជំនុំជម្រះ សម្រេច

(១) សហមេធាវីអាចដាក់សារណាមិនឲ្យលើសពី ១៥ ទំព័រ អំពីបញ្ហាយុត្តាធិការដែលបានលើកឡើងក្នុងកថាខ័ណ្ឌទី ៥ ដល់ទី ១៤ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រឹមម៉ោង ១៦:០០ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨

(២) សហព្រះរាជអាជ្ញាអាចដាក់សេចក្ដីសន្និដ្ឋានមិនឲ្យលើសពី ១៥ ទំព័រ ជាភាសាអង់គ្លេស និងភាសាខ្មែរក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសារណារបស់សហមេធាវី។ ៕

ភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

**ប្រាក់ គីមសាន**